# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៤៤..អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការលុបអនុក្រឹត្យស្ដីពីការបង្កើតខុទ្ទកាល័យសម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្ដីពីការតែងតាំងមន្ត្រីសង្ឃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការបង្កើតខុទ្ទកាល័យ សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៧៣ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងមន្ត្រីសង្ឃ
- យោងតាមសំណើរបស់ សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី នៃព្រះរាជាណាចក្រកម្ពុជា

## សំរេច

**មាត្រា ១:-**

ត្រូវបានលុបអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការបង្កើតខុទ្ទកាល័យ សម្ដេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៣៧៣ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងមន្ត្រីសង្ឃ ។

**មាត្រា ២:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ